(108) 100/1? 5 May 20

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

សាលាឧទ្ធរណ៍

**សំណុំរឿងសភាព្រហ្មទណ្ឌ**
លេខ: ១២៦៧
ចុះថ្ងៃទី២២-១០-២០១៨
**សាលដីកា**
លេខ:២៨ក្រVសស
ចុះថ្ងៃទី២៦-០២-២០២០

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៧១៤/០១៥ចុះថ្ងៃទី១៦-៧-២០១៤បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ដែលមានសមាសភាពដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

<u>ដើម្បីជំនុំជម្រះលើសំណុំរឿងសភាព្រហ្មទណ្ឌលេខ : ១២៦៧ ចុះថ្ងៃទី ២២-១០-២០១៨ របស់សាលាឧទ្ធរណ៍ដែលមាន:</u>

១-ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកបររថយន្តតាក់ស៊ី មានទីកន្លែងកំណើត និង បច្ចុប្បន្ននៅភូមិព្រៃ[redacted] ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ[redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន( ដើមបណ្តឹងឧទ្ធរណ៍) ឃុំខ្លួនថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១៧ (ពន្ធនាគារខេត្តស្វាយរៀង) ។

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទលោក អ៊ាន សំអាត

២-ជនជាប់ចោទឈ្មោះ [redacted] សូនី ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកបររថយន្តតាក់ស៊ី មានទីកន្លែងកំណើតនិងបច្ចុ[redacted] ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ឪពុកឈ្មោះ[redacted]រ) ម្តាយឈ្មោះ[redacted](រ) ប្រពន្ធឈ្មោះ [redacted]មានកូន០២នាក់ ទោសពីមុនគ្មាន ដើមបណ្តឹងឧទ្ធរណ៍ ឃុំខ្លួនថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ (ពន្ធនាគារខេត្តស្វាយរៀង) ។

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទលោក[redacted]សម្បត្តិ





Scanned with CamScanner

ជាប់ចោទពីបទ៖ **ឃាតកម្មដោយមានទារុណកម្ម និង អំពើរំលោភសន្ថវៈ** ប្រព្រឹត្តនៅភូមិតាពៅ 10/11
សង្កាត់បារិត ក្រុងបារិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២០៥** នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណី

១.ឈ្មោះ [redacted] **ស្រីឡូត** ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅសព្វថ្ងៃនៅភូមិដូនម៉ៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។

២.ឈ្មោះ [redacted] **សុវណ្ណ** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅសព្វថ្ងៃនៅភូមិដូនម៉ៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោក [redacted] **ស៊ីណារេត**

## __ឯរឿងហេតុមានដូចតទៅ__

កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ សមត្ថកិច្ចជំនាញនគរបាលព្រហ្មទណ្ឌខេត្តស្វាយរៀង បានទទួលពាក្យបណ្តឹងពីឈ្មោះ **ប៊ូយ សុវណ្ណ** ប្តឹងឲ្យសមត្ថកិច្ចជួយស្រាវជ្រាវរកកូនស្រីឈ្មោះ [redacted] សុម៉ាលីន ដែលបានបាត់ខ្លួនកាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ នៅពេលដែលកូនស្រីខ្លួនត្រឡប់មកពីផ្ទះនៅខេត្តព្រះវិហារមកធ្វើការនៅខេត្តស្វាយរៀងវិញ នៅពេលមកដល់ចំណុចផ្សារជីភូក៏បាត់ដំណឹង ។ ក្រោយទទួលបានពាក្យបណ្តឹងសមត្ថកិច្ចបានធ្វើការស្រាវជ្រាវកំណត់មុខសញ្ញានិងឈានទៅដល់ការឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] **សុជាតិ** ដើម្បីធ្វើការសាកសួរនៅចំពោះមុខសមត្ថកិច្ចឈ្មោះ [redacted] **សុជាតិ** បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តអំពើរំលោភសម្លាប់នារីរងគ្រោះនៅចំណុចភូមិតាពៅ សង្កាត់បារិត ក្រុងបារិត ខេត្តស្វាយរៀងកាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ នោះពិតមែន ដោយធ្វើសកម្មភាពជាមួយបក្ខពួកម្នាក់ទៀតឈ្មោះ [redacted] សូនី ជាអ្នករត់តាក់ស៊ីដូចគ្នា ។ ក្នុងពេលនោះសមត្ថកិច្ចក៏បានធ្វើការឆែកឆេរក្នុងរថយន្តម៉ាកហាយលែនឌ័រពណ៌សជារបស់ឈ្មោះ [redacted] សុជាតិ រកឃើញខ្សែកកាឡៃ ចំនួន **០១**ខ្សែ និងចិញ្ចៀនដាំត្បូងពណ៌សកាឡៃ០១វង់របស់ជនរងគ្រោះនៅក្នុងរថយន្តទៀតផង ។ នៅក្នុងថ្ងៃដដែលនោះដោយមានកិច្ចសហការជាមួយកំលាំងជំនាញនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌក៏បានឃាត់ខ្លួនជនសង្ស័យដែលជាបក្ខពួកម្នាក់ទៀតឈ្មោះ [redacted] សូនី នាំមកសាកសួរនឹងកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមច្បាប់ ។

__បានឃើញសាលក្រមព្រហ្មទណ្ឌលេខ:២០០ “ឃ” ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀងបានសម្រេចសេចក្តីដូចតទៅ ៖__

-ផ្តន្ទាទោសលើ៖

ក-ឈ្មោះ [redacted] សុជាតិ ភេទប្រុស អាយុ ៣៥ឆ្នាំ

ខ-ឈ្មោះ [redacted] សូនី **ហៅ** មុន្នី ភេទប្រុស អាយុ៣២ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ **អស់មួយជីវិត** ពីបទ: **ឃាតកម្មដោយមានទារុណកម្ម** និងអំពើរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាពៅ សង្កាត់បារិត ក្រុងបារិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រ **២០៥** នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុជាតិ និងឈ្មោះ [redacted] សូនី ហៅមុន្នី ត្រូវរួមគ្នាសងប្រាក់សំណងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុវណ្ណ ចំនួន **៦០.០០០**(ប្រាំមួយម៉ឺនដុល្លារអាមេរិច )។



Scanned with CamScanner

១០០/១៧

៣-វត្ថុតាងរូមមាន:

-រថយន្តម៉ាកហាយលេនឌ័ពណ៌សពាក់ស្លាកលេខភ្នំពេញ 2 AQ - 0525 និង ទូរសព្ទ័ដៃចំនួន០៤គ្រឿង ដែលបានដកហូតពីជនជាប់ចោទត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

-រថយន្តម៉ាក LEXUS RX 300 ពណ៌ទឹកមាស ពាក់ស្លាកលេខ ភ្នំពេញ 2AL- 4238 ផលិតក្នុងឆ្នាំ២០០០ ដែលមានលេខម៉ាស៊ីន 1 MZ 1396838 និងលេខតួ JT 6 HF 10 U7 Y 0102473 និងចង្កឹះសោរចំនួន ០១ ត្រូវប្រគល់ឲ្យទៅម្ចាស់ដើមប្រើប្រាស់ជាកម្មសិទ្ធិវិញ ។

-ខ្សែកកាខ្សែ០១ ចិញ្ចៀនកាខ្សែ ០១វង់ មានដាំត្បូងពណ៌សត្រូវប្រគល់ឲ្យទៅឈ្មោះ [redacted] ស្រីឡូត ដែលត្រូវជាម្តាយសពជនរងគ្រោះវិញ ។

-ខ្សែដៃប្លាកទី០១ខ្សែទម្ងន់(៣៤៣លីទីកល)ចិញ្ចៀនក្រាមាស១វង់ទម្ងន់០៣ជី(មាស៩៩៩) វ៉ាលីដាក់ខោអាវពណ៌ក្រហម ០១ អត្តសញ្ញាណបណ្ណ័សញ្ជាតិខ្មែរ ០១ ឈ្មោះ [redacted] សូនី ត្រូវប្រគល់ឲ្យទៅម្ចាស់ដើមវិញ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុជាតិ ឈ្មោះ [redacted] សូនី និង ដើមបណ្តឹងរដ្ឋប្បវេណី ។

ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញសេចក្តីសុំប្តឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ សុំប្តឹងឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសម្រេចទី១(ក)ទី២ និង ទី៣ នៃសាលក្រមព្រហ្មទណ្ឌលេខ ២០០ឃ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨របស់សាលាដំបូងខេត្តស្វាយរៀង។

-បានឃើញសេចក្តីសុំប្តឹងឧទ្ធរណ៍លេខ៤៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោ[redacted]សូនី សុំប្តឹងឧទ្ធរណ៍ត្រង់សេចក្តីសម្រេចចំណុចទី១ និង ទី២ នៃសាលក្រមព្រហ្មទណ្ឌលេខ ២០០ឃ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨របស់សាលាដំបូងខេត្តស្វាយរៀង ។

-បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

<u>នាពេលសវនាការ</u>

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីឡូត (វត្តមាន)

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោក [redacted] ស៊ុណាកេត (វត្តមាន)

-ជនជាប់ចោទឈ្មោ[redacted]សុជាតិ (វត្តមាន)មេធាវី លោ[redacted] សំអាត (វត្តមាន)

-ជនជាប់ចោទឈ្មោះឈ្មោះ [redacted] សូនី ហៅ មុន្នី (វត្តមាន) មេធាវីលោក [redacted] សម្បត្តិ (វត្តមាន)

ប្រធានក្រុមប្រឹក្សា: អានរបាយការណ៍បញ្ជាក់អង្គហេតុនៃរឿងក្តី

ជនជាប់ចោ[redacted]សុជាតិ បានឆ្លើយបញ្ជាក់ថា ខ្ញុំពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ខ្ញុំប្តឹងឧទ្ធរណ៍មកដើម្បីសុំបន្ធូរបន្ថយទោសត្រឹម១៥ឆ្នាំ និង សំណងសុំសងចំនួន៥ពាន់ដុល្លាអាមេរិក ។ នៅថ្ងៃកើតហេតុខ្ញុំបានដឹកជនរងគ្រោះពីអូរឡាំពិកចេញទៅច្បារអំពៅបានដាក់មួយបាន២នាក់ទៀតហើយខ្ញុំបានតេទៅ [redacted] សូនី ប្រាប់ថាមានស្រីស្អាតជិះក្នុងឡានរបស់ខ្ញុំ ពេលទៅតាមផ្លូវខ្ញុំដាក់មួយហូរហែរពេលដល់អ្នកលឿងឡានរបស់ ផ្លេក សូនី មកអែបឡានខ្ញុំៗ បានចុចកញ្ចក់ឡានប្រាប់សូនី ថា មានស្រីស្អាតជិះ នៅបាំងក្រោយក្នុងឡានខ្ញុំៗបើកឡានជូនមួយដាក់តាមគោលដៅអស់បានណាត់ជួប [redacted] សូនី នៅមន្ទីរពេទ្យ ជីភូ ឈ្មោ[redacted]សូនី បានឡើងជិះឡានខ្ញុំនៅបាំងខាងក្រោយជាមួយជនរងគ្រោះហើយប្រាប់ជនរងគ្រោះថាជិះផ្លូវកាត់ពេលជិះតាមផ្លូវដល់ថ្នសបំបែកទៅបាវិតឈ្មោះ [redacted] សូនី ចាប់ផ្តើមធ្វើសកម្មភាពចងដៃជនរងគ្រោះទៅក្រោយប្រគាយប្រគប់គ្នា និង បានចាប់សង្កត់ជនរងគ្រោះរំលោភនៅលើឡាន ។ តាមផ្លូវមិនសូវមានប្រជាជនទេ ពេលមកដល់ផ្លូវកែងចូលរោងចក្រយើងមេឌីកឈឺបំឡានមុន្នី ចុះពីឡាន ខ្ញុំក៏បានទៅរំលោភជនរងគ្រោះម្តងពេលនោះជនរងគ្រោះសន្លប់រួចហើយ ។ ឈ្មោ[redacted]សូនី ជាអ្នកធ្វើសកម្មភាពយកកន្សែងទាក់កកន្ទ្រាក់ជនរងគ្រោះទម្លាក់ពីលើឡាន ខ្ញុំបានប្រាប់ សូនី ថា កុំសម្លាប់ជនរង



Scanned with CamScanner

គ្រោះអីតែវាថាខ្លាចបែកការ ។ ឡានរបស់ខ្លួនពណ៌ស ឡាន [redacted]សូនី លុចស៊ីស៣០០ ពីមុនមកពុំដែលមានទំនាស់ជាមួយ មុន្នី ហើយខ្ញុំពុំបានឆ្លើយទម្លាក់កំហុសលើ មុន្នី ទេ ខ្ញុំស្គាល់ [redacted]សូនី តាំងពីតូចមក ម្លេះចម្លើយនេះជាការពិត ។ ជិះឡានពីជីភូទៅព្រែកតាញ់ប្រើពេលប្រហែល២០នាទី ។ កាលមុនធ្លាប់រំលោភជនជាតិវៀតណាមជាមួយ[redacted]ូនី មែន តែភ្លេចភ្លាំងអស់ហើយក្រោយពេលប្រព្រឹត្តរួចខ្ញុំបើកឡានត្រឡប់មកផ្ទះវិញ ។ មុនពេលសមត្ថកិច្ចឃាត់ខ្លួននៅផ្ទះរបស់ខ្ញុំមានកម្មវិធីសូត្រមន្តពេលល្ងាចមានកម្មវិធីផឹកស៊ីពេលនោះ សូនី បានទៅចូលរួមដែរខ្លួនពុំដែលមានទំនាស់ជាមួយ សូនី ទេ ។

ជនជាប់ចោទឈ្មោះ [redacted] សូនី បានឆ្លើយបញ្ជាក់ថា ខ្ញុំមិនព្រមទទួលទោសនិងសងសំណងទេព្រោះខ្ញុំមិនបានចូលរួមរំលោភសម្លាប់លើជនរងគ្រោះឡើយ នៅថ្ងៃទី០២-០៨-២០១៧ ម៉ោង៨ព្រឹកខ្ញុំដឹកភ្ញៀវជនជាតិម៉ាកាវពីកាស៊ីណូបាវិតទៅព្រលានយន្តហោះភ្នំពេញនៅម៉ោង១០:៥០នាទីជាងពេលដាក់ជនជាតិចិនចុះហើយនៅចាំយកភ្ញៀវត្រឡប់ទៅខេត្តស្វាយរៀងវិញ ។ ខ្ញុំទៅដល់ប្រសូត្រម៉ោង៤ ជាងហើយចំងាយពីប្រសូត្រទៅ ភូមិព្រែកតាញ់យចំងាយ ១០km ជាង មុនចូលផ្ទះខ្ញុំដឹកតុ កៅអីអីណុក ឲ្យឈ្មោះ [redacted]ស៊ីភួន ខ្ញុំមិនបានទូរស័ព្ទឬណាត់ជួប [redacted]សុជាតិ នៅមន្ទីរពេទ្យជីភូហើយក៏ពុំបានជិះឡានចាប់ជនរងគ្រោះចងនិងចូលរួមរំលោភជនរងគ្រោះទេ ។ ខ្ញុំធ្លាប់ឈ្លោះគ្នាជាមួយឈ្មោះ[redacted]សុជាតិ រឿងព្រំដីតែមិនបានដាក់ពាក្យចូលតុលាការទេ ខ្ញុំធ្លាប់វៃគ្នាជាមួយឈ្មោះ[redacted]សុជាតិ រឿង ដណ្តើមមួយគ្នា ។ នៅម៉ោង៤:៣០នាទីល្ងាច ខ្ញុំមិនបានដឹកមួយទៅណាទេ បន្ទាប់ពី ដឹកតុ កៅអី បានចូលផ្ទះខ្ញុំដឹកមួយចិនមានលេខកូតចូលព្រលានយន្តហោះភ្នំពេញតែយកក្រដាសនោះហែកចោល ព្រោះពុំបានគិតថាជាឯកសារ ។ ប្អូនថ្លៃខ្ញុំមានរឿងរំលោភជនជាតិវៀតណាមខ្លួនមិនដឹងដែរ ។ សមត្ថកិច្ចបានវាយបាតជើងខ្លួនឲ្យឆ្លើយហើយឈ្មោះ[redacted] សុជាតិ បានឆ្លើយថា មិនស្គាល់លេខទូរស័ព្ទ ខ្ញុំតែទៅវា ។ ភ្ញៀវយកទៅពោធិចិនតុង២នាក់នៅថ្ងៃកើតហេតុថ្ងៃទី០២ ខែ សីហា ឆ្នាំ២០១៧ ។ ខ្ញុំមកឡើងផ្ទះ [redacted]សុជាតិ ពេលនោះខ្ញុំដឹកឥវ៉ាន់ឲ្យមួយដាក់កូនកង់នៅផ្ទះជិតនោះឈ្មោះ[redacted]សុជាតិ បានមកក្រៀកករខ្ញុំឲ្យចូលផឹកហើយខ្ញុំក៏ផឹកបានគន្លះកំប៉ុងរួចឲ្យលុយ ១៥.០០០រៀល ដោយសារអ្នកផឹក សុំទិញស្រាបៀរ ។ ខ្ញុំមិនបានជួប សុជាតិ នៅអ្នកលឿងទេ ហើយក៏មិនដឹងមានករណីរំលោភនៅបាវិតដែរ ។ រឿងរំលោភជនជាតិវៀតណាមខ្ញុំដឹងតែមិនបានទៅមើលនោះទេ ខ្ញុំមានលេខទូរស័ព្ទតែត្រូវតុលាការដកយកទុកហើយពេលគេចាប់ខ្ញុំបើសិនខ្ញុំទូរស័ព្ទទៅ[redacted]ុជាតិ រឿងណាត់ជួបនៅមន្ទីរពេទ្យជីភូមែនគាត់ស្គាល់លេខខ្ញុំហើយ ឈ្មោ[redacted] សុជាតិ ឆ្លើយទំលាក់កំហុសដាក់ខ្ញុំព្រោះមានគំនុំនឹងខ្ញុំៗ សុំឲ្យតុលាការដោះលែងខ្ញុំវិញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ស្រីឡូត បានឆ្លើយបញ្ជាក់ថាកូនស្រីខ្ញុំ ឈ្មោះ [redacted]ម៉ាលីន នៅថ្ងៃទី០២-០៨-២០១៧ នាងធ្វើដំណើរចេញពីផ្ទះមកធ្វើការនៅកាស៊ីណូបាវិតខ្ញុំបានទូរស័ព្ទសួរកូនដល់ណាហើយកូនប្រាប់ពុំទាន់ដល់ទេ មុនពេលកើតហេតុខ្ញុំបាត់ការទាក់ទងជាមួយកូននៅវេលាម៉ោង៦ល្ងាចទាក់ទងពុំបានខ្ញុំភ័យខ្ញុំបានមកស្វាយរៀងដាក់ពាក្យបណ្តឹងពីមុនមកកូនពុំដែលមានទំនាស់ជាមួយអ្នកណាទេ ។ សំណូមពរសុំតម្កល់សាលក្រមសាលាដំបូង ។

សាក្សីឈ្មោះ[redacted]ស៊ីភួន បានឆ្លើយបញ្ជាក់ថាខ្ញុំជាអ្នកស្រុកភូមិជាមួយឈ្មោះ[redacted] សូនី ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ម៉ោង៤:៣០នាទីល្ងាចឈ្មោះ[redacted] សូនី បានមកយកតុកៅអីអីណុកពីផ្ទះខ្ញុំលក់ឲ្យមួយបានកត់វិក័យប័ត្រម៉ោង៤ទើបខ្ញុំចាំថ្ងៃខែដឹកតុនេះហើយ ឈ្មោះ សូនី ទៅទិញម្ហូបខ្ញុំចាំព្រោះដល់ម៉ោង

រោងចក្រចេញខ្ញុំលក់ដូរនៅផ្សារប្រសូតិ កៅអី១០ តុ០១ ប្ដីខ្ញុំអ្នកលើកដាក់ឡានរបស់សូនី រឿងឃាតកម្មរំលោភសម្លាប់នារីកាស៊ីណូនៅកន្លែងនិងម៉ោងប៉ុន្មានខ្ញុំពុំបានឹងទេ ។

សាក្សីឈ្មោ[redacted]សារិន បានឆ្លើយបញ្ជាក់ថា ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ឈ្មោះ សូនី បាន ដឹកតុឲ្យខ្ញុំនៅព្រៃតាញ៉យ កៅអី១០ តុ០១ ដឹកមកដល់ម៉ោងប្រហែល៥ជាងល្ងាចខ្ញុំទៅយកតុនៅផ្ទះ សូនី ខ្ញុំមិនបានយកវិក័យប័ត្រឲ្យតុលាការទេ តំលៃតុ និង កៅអី ៦០$ តម្លៃដឹកពុំចាំព្រោះដឹកយូរហើយ នៅតុលាការខ្ញុំឆ្លើយមិនឃើញខោអាវរបស់ សូនី ប្រលាក់ឈាមអ្វីទេ ។

សាក្សីឈ្មោះ[redacted] ត្រា បានឆ្លើយបញ្ជាក់ថា សុំរក្សាចម្លើយនៅសាលាដំបូងដដែលម៉ោងប្រហែល៥ ជាងល្ងាចខ្ញុំឃើញឈ្មោះ សូនី ហៅឈ្មោ[redacted]ស៊ីតួន , [redacted]សារិ មកយកកៅអី និង តុ ខ្ញុំមានស្រុកកំណើតនៅព្រៃញ៉យជាមួយគ្នា ខ្ញុំត្រូវជាម្ដាយមីង[redacted]សូនី ខាងម្ដាយ ។

សាក្សីឈ្មោះ[redacted] ណា បានឆ្លើយបញ្ជាក់ថា នៅសាលាដំបូងឆ្លើយម្ដងរួចហើយ ខ្ញុំសុំឲ្យតុលាការជួយរកយុត្តិធម៌អោយឈ្មោះ [redacted] សូនី ខ្ញុំឃើញឈ្មោះនេះដឹកតុឲ្យ [redacted] សារិ ម៉ោងប្រហែល ៥:៣០នាទីល្ងាចបន្ទាប់មកខ្ញុំឃើញវាលាងឡានរបស់វានៅមុខដល់ម៉ោងប្រហែល ៦ល្ងាច ឈ្មោះ [redacted] សូនី ជាអ្នកជិតខាងគ្នា ។

សាក្សីឈ្មោ[redacted]សូន្យ បានឆ្លើយបញ្ជាក់ថាខ្ញុំត្រូវជាប្រពន្ធរបស់ផ្លេក សូនី ខ្ញុំបានឆ្លើយនៅសាលាដំបូងរួចហើយ ថ្ងៃកើតហេតុប្ដីខ្ញុំដឹកភ្ញៀវចិនទៅភ្នំពេញហើយល្ងាចត្រឡប់មកវិញ ពេលដល់ផ្ទះម៉ោង ៤ ជាង ។ ប្ដីខ្ញុំនៅផ្ទះដឹកតុមកដល់ប្របែបេ ម៉ោង៥ជាង ហើយគ្មានទៅណាទេខ្លួនបានកោស ខ្យល់ឲ្យប្ដីផង។

លោក [redacted] ស៊ីណាកេត មេធាវីដើមបណ្ដឹងផ្ដល់សេចក្ដីសន្និដ្ឋានៈ

ក្រោយពីសិក្សាសំណុំរឿងនេះនិងស្ដាប់ចម្លើយនាពេលសវនាការឈ្មោះ [redacted] សុជាតិ ឆ្លើយសារភាពថា បានចូលរួមប្រព្រឹត្តរំលោភសេពសន្ថវៈហើយសម្លាប់កូនរបស់កូនក្ដីខ្ញុំ ការរំលោភសម្លាប់គឺ ជនជាប់ចោទធ្វើជាមួយ [redacted] សូនី ដោយស៊ីចង្វាក់ទៅនិងភស្ដុតាងដែលសមត្ថកិច្ចបានដកហូតពីឡានរបស់ជនជាប់ចោទ និង ចម្លើយ [redacted] សុជាតិ ថា បានចូលរួមជាមួយឈ្មោ[redacted] សូនី ចំណែក [redacted] សូនី ឆ្លើយបដិសេធនិងមានការប្រែប្រួលព្រោះថាចម្លើយផ្ទុយ និង ចម្លើយសាក្សីថានៅម៉ោង ៥:៣០នាទី ឃើញសូនី មកដល់ផ្ទះតែជនជាប់ចោទថាម៉ោង៤ជាង។ចម្លើយឈ្មោះផ្លេក សូនីថាឈ្លោះគ្នាជាមួយ [redacted]សុជាតិ រឿងដីម្ដង ថាឈ្លោះគ្នានៅចំណតឡានដណ្ដើមមួយ តែមនុស្សឈ្លោះគ្នាមិនអាចបក់ដៃជួបគ្នាទេហើយពុំអាចទៅដឹកស៊ីនៅផ្ទះ [redacted]ុជាតិ ទេ សំណូមពរសុំតម្កល់សាលក្រមសាលាដំបូងទុកជាបានការ ។

តំណាងមហាអយ្យការផ្ដល់សេចក្ដីសន្និដ្ឋានៈ បណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទ [redacted] សុជាតិ និងជនជាប់ចោទ [redacted]សូនី ធ្វើឡើងតាមកំណត់ច្បាប់ ។ តាមអង្គហេតុនិងតាមកោសលវិច័យរបស់សមត្ថកិច្ចពិតជាមានការរំលោភសម្លាប់និងធ្វើទារុណកម្មលើជនរងគ្រោះបណ្ដាលឲ្យស្លាប់ត្រូវផ្ដន្ទាទោសជនជាប់ចោទតាមមាត្រា២០៥ ក្រមព្រហ្មទណ្ឌ ឈ្មោ[redacted]សុជាតិ ទទួលស្គាល់ថាបានរំលោភសេពសន្ថវៈនិងសម្លាប់ជនរងគ្រោះ មានពិរុទ្ធភាពលើ [redacted] សុជាតិ សុំតម្កល់សាលក្រមលើ[redacted]សុជាតិ ។ ចំពោះចម្លើយ[redacted] សុជាតិ ដាក់បន្ទុកលើឈ្មោះ[redacted] សូនី ថា ជាអ្នកចាប់ជនរងគ្រោះចង ហើយរំលោភជនរង



Scanned with CamScanner

គ្រោះមុនរួចទើប [redacted] សុជាតិ រំលោភតាមក្រោយ ពុំគួរឲ្យជឿព្រោះ [redacted] សុជាតិ ជាអ្នកផ្តើមគំនិតមុនជាអ្នកដឹកជនរងគ្រោះពុំអាចឲ្យមិត្តភ័ក្តិរំលោភលើស្រីស្អាតមុនទេ ចំពោះករណីសម្លាប់លើជនរងគ្រោះ [redacted] សុជាតិ ថា [redacted] សូនី ជាអ្នកយកខ្សែទាក់កតែជនជាប់ចោទ [redacted] សូនី បដិសេធដែរ ។ គ្មានអង្គហេតុចោទប្រកាន់ក្នុងបទល្មើសអំពើរំលោភសេពសន្ថវៈនារីវៀតណាម ។ ឈ្មោះ [redacted] សូនី បានឆ្លើយថាខ្លួនមិនបានប្រព្រឹត្តរំលោភនិងសម្លាប់ជនរងគ្រោះរហូតតាំងពីសមត្ថកិច្ចនគរបាលដល់ពេលសវនាការនេះ ។ សូនីបានបញ្ជាក់ថា ខ្លួនធ្លាប់មានទំនាស់និងគំនុំជាមួយ [redacted] សុជាតិ ហើយឈ្មោះ [redacted] សុជាតិ ឆ្លើយទំលាក់កំហុសដាក់ខ្លួន សកម្មភាពនេះពុំអាច [redacted] សុជាតិ ធ្វើម្នាក់ឯងបានទេ អាចមានអ្នកផ្សេងមានជនផ្សេងទៀតប្រព្រឹត្តជាមួយ [redacted] សុជាតិ ប៉ុន្តែពុំមែនឈ្មោះ [redacted] សូនី នេះទេ ក៏ថាបាន ។ សាក្សី៥នាក់នេះបើពិនិត្យអាកប្បកិរិយាគឺជាមនុស្សស្លូតបូតហើយចម្លើយក៏ពុំមានប្រែប្រួលដែរសាក្សីបានឃើញ [redacted] សូនីនៅដឹកគុកៅអីនិងនៅផ្ទះពីម៉ោង៤ម៉ោង៥ និងម៉ោង ៦ ល្ងាចនោះ ដើមបណ្តឹងថា ម៉ោង៦ទូរស័ព្ទទាក់ទងកូនលែងចូល ចម្លើយ [redacted] សូនី ឆ្លើយសំខាន់នៅមន្ត្រីនគរបាលយុត្តិធម៌ថា ថ្ងៃកើតហេតុពុំបានទាក់ទងជាមួយ [redacted] សុជាតិ ទេ ការដាក់ទោសមួយជីវិត តុលាការពិចារណាឲ្យបានដិតដល់អាចចាត់របៀបឆែកលេខទូរស័ព្ទដែល [redacted] សុជាតិ តេទៅ [redacted] សូនី [redacted] សូនី តេ [redacted] សុជាតិ មែនឬទេ ។ សាលក្រមលើឈ្មោះ [redacted] សុជាតិ គួរតម្កល់ ចំណែកឈ្មោះ [redacted] សូនី ទុកសិទ្ធិឲ្យក្រុមប្រឹក្សាសម្រេចឲ្យត្រឹមត្រូវផ្តល់យុត្តិធម៌ជាប្រយោជន៍គូភាគី ។

លោក [redacted] សំរាត មេធាវីការពារសិទ្ធិជនជាប់ចោទ [redacted] សុជាតិ ផ្តល់សេចក្តីសន្និដ្ឋាន ៖

១-អង្គហេតុថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ មានអំពើឃាតកម្មរំលោភសេពសន្ថវៈដោយធ្វើទារុណកម្ម និង សម្លាប់ជនរងគ្រោះហើយកូនក្តីខ្ញុំបានឆ្លើយសារភាពរួចហើយៗបទល្មើសនេះកូនក្តីខ្ញុំពុំអាចធ្វើតែម្នាក់ឯងបានទេ ការដែលកូនក្តីខ្លួនឆ្លើយដាក់ឈ្មោះ [redacted] សូនី ព្រោះតែ [redacted] សូនី ចាប់ចងដៃរួចរំលោភជនរងគ្រោះព្រោះជាកាលៈទេសៈក្នុងការប្រព្រឹត្តបទល្មើសនេះកូនក្តីខ្ញុំកំពង់បើកឡាន កូនក្តីខ្លួនឆ្លើយដាក់បន្ទុកលើ [redacted] សូនី មិនមានផលប្រយោជន៍អ្វីដែរ គាត់ទទួលស្គាល់ទោសហើយប្តឹងឧទ្ធរណ៍សុំសំរាលទោសតាមមាត្រា៩៣,៩៤ នៃក្រមព្រហ្មទណ្ឌ ។

២-ការរឹបអូសទ្រព្យសម្បត្តិត្រង់ចំណុចទី ៣ កូនក្តីខ្លួនប្តឹងឧទ្ធរណ៍សំរាលទោសតាមមាត្រា៩៣,៩៤ សុំបន្ថយសំណងធ្ងន់ពេក និង សុំប្រគល់រថយន្តឲ្យកូនក្តីខ្លួនវិញ ដើម្បីលក់យកប្រាក់ចិញ្ចឹមប្រពន្ធកូនព្រោះថា ប្រពន្ធនិងកូនៗរបស់កូនក្តីខ្លួនមានជីវភាពក្រីក្រណាស់ ។

មេធាវី [redacted] សម្បត្តិ មេធាវីការពារសិទ្ធិជនជាប់ចោទ [redacted] សូនី ផ្តល់សេចក្តីសន្និដ្ឋាន ៖

រឿងក្តីនេះពិតជាមានអង្គហេតុរំលោភសេពសន្ថវៈ និង ធ្វើទារុណកម្មបណ្តាលឲ្យស្លាប់ជនរងគ្រោះមែន ការសម្រេចរបស់សាលាដំបូងមានវិការៈគឺពុំត្រឹមត្រូវត្រង់តុលាការផ្តន្ទាទោសលើ [redacted] សូនី គប្បីសាលាឧទ្ធរណ៍ពិចារណា មិនមានភស្តុតាងណាដាក់បន្ទុកលើកូនក្តីខ្ញុំទេ ទោះបីមានការធ្វើទារុណកម្មពីសមត្ថកិច្ចដូចតំណាងមហាអយ្យការសន្និដ្ឋាន ជនរងគ្រោះស្លាប់មានការសោកសង្រេងតែការដាក់ទោសមនុស្សខុសក៏អយុត្តិធម៌ ចម្លើយនាពេលសាលាឧទ្ធរណ៍នេះ [redacted] សុជាតិ ឆ្លើយមានការប្រែប្រួលនិងចម្លើយនៅតុលាការស្វាយរៀង [redacted] សុជាតិ ថា មានស្រីស្អាតតែពេលនេះ ផ្អែក សូនី អ្នកសួរ ។ ការប្រឌិតរឿងថា ឈ្មោះ [redacted] សូនី បានយកទូរស័ព្ទអ្នកផ្សេងមកខលគាត់ [redacted] សុជាតិ ថាឈ្មោះ [redacted] សូនី

រំលោភមុនគាត់ព្រោះគាត់ជាអ្នកបើកឡានការប្រឌិតរឿងរំលោភជនរងគ្រោះជាជនជាតិវៀតណាមជាមួយ កូនក្តីខ្ញុំតែគ្មានសំណុំរឿងទេ គឺគ្រាន់តែប្រឌិតដើម្បីចោទកូនក្តីខ្ញុំថា ចូលរួមប្រព្រឹត្តបទល្មើសដ៏ធ្ងន់ធ្ងរនេះ ហេតុអ្វីតុលាការមិនជឿកូនក្តីខ្ញុំ ជឿតែឈ្មោ[redacted]ុជាតិ តុលាការជឿតែលើ [redacted]សុជាតិ ដាក់គុកកូនក្តី ខ្ញុំមួយជីវិត សាក្សីឃើញឡានចុះហេតុអីមិនឃើញអំពើរំលោភ សាក្សីដាក់បន្ទុក [redacted]ុ ជាតិ ឡានរបស់ [redacted] សុជាតិ គ្រឿងអលង្ការរបស់ជនរងគ្រោះនៅឡានរបស់ [redacted]ុជាតិ មិនបានដាក់បន្ទុកកូនក្តីខ្ញុំទេ គប្បីតំណាងមហាអយ្យការជាអ្នករកភស្តុតាងដាក់បន្ទុកត្រូវកំណត់ឲ្យបានច្បាស់លាស់សិន ហេតុអីមិនរកភស្តុតាងដោះបន្ទុកមិនត្រូវឲ្យកូនក្តីខ្ញុំរងអំពើអយុត្តិធម៌ទេ គប្បីពិចារណាទូរស័ព្ទ ២ គ្រឿងរបស់[redacted] សុនី ត្រូវបានលុបលេខខលទំនាក់ទំនងអស់ហេតុអីទិន្នន័យត្រូវបាត់ចម្លើយរបស់ [redacted]ុជាតិ មានវិការៈសមត្ថកិច្ចនគរបាលថា ដាក់ភស្តុតាងកូនក្តីខ្ញុំធ្លាប់ឈ្លោះគ្នាជាមួយ[redacted] សុជាតិ តែ បែរជាពុំមានវិញ ។ ចម្លើយសាក្សីឈ្មោះត្រង់ស៊ីសង្វាក់ទៅចម្លើយកូនក្តីខ្ញុំបញ្ជាក់ថាថ្ងៃកើតហេតុចាប់ពីម៉ោងល្ងាចទៅគឺកូនក្តីខ្ញុំនៅផ្ទះខ្ញុំ សុំគាំទ្រសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ខ្ញុំ សុំសាលាឧទ្ធរណ៍ចាត់របៀបដើម្បីស៊ើបអង្កេតបន្ថែមលើប្រពន្ធ័ និង លេខទូរស័ព្ទតើកូនក្តីខ្ញុំបានខលចូលទៅទូរស័ព្ទរបស់[redacted] សុជាតិ ទេ មុនកើតហេតុ ។ ហេ[redacted]សុជាតិ ថាលេខពុំស្គាល់ខលទៅគាត់ បើថាកូនក្តីខ្ញុំជាមិត្តភក្តិហើយហៅបែរជាស្គាល់លេខ គប្បីលើកលែងចោទលើកូនក្តីខ្ញុំឲ្យមានសេរីភាពវិញ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនិងបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ សុំប្តឹងឧទ្ធរណ៍គ្រង់ចំណុចសេចក្តីសម្រេចទី១(ក) ទី២ និងទី៣ នៃសាលក្រមព្រហ្មទណ្ឌលេខ **២០០ឃ** ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចលើកមកជំនុំជម្រះបាន ។

២-ពាក្យបណ្តឹងឧទ្ធរណ៍លេខ៤៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទ ផ្លេក សុនី សុំប្តឹងឧទ្ធរណ៍គ្រង់សេចក្តីសម្រេចចំណុចទី១ និង ទី២ នៃសាលក្រមព្រហ្មទណ្ឌលេខ **២០០ឃ** ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចលើកមកជំនុំជម្រះបាន ។



Scanned with CamScanner

៣-ជនជាប់ចោទ[redacted] សុជាតិ បានឆ្លើយសារភាពគ្រប់ដំណាក់កាលថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ខ្លួនបានដឹកមួយប្រុសៗ៥នាក់ និង ស្រីម្នាក់ចេញពីភ្នំពេញទៅខេត្តស្វាយរៀង ពេលដល់អ្នកលឿងបានដាក់មួយប្រុសៗពីរនាក់ចុះហើយបានជួបឈ្មោះ មុន្នី [redacted]សូនី )អ្នកបើកឡានតាក់ស៊ីដែរ ពេលនោះបើកឡានយឺតចុចកញ្ចក់មកអែបឡានខ្លួនៗបានប្រាប់ថាមានស្រីស្អាត ពេលនោះ មុន្នី ថាយកទៅពេលដាក់មួយប្រុសៗចុះអស់មកដល់ស្វាយរៀង ឈ្មោះ មុន្នី បានទូរស័ព្ទមកខ្លួនថា វានៅចាំនៅមុខមន្ទីរពេទ្យជីភូពុំចាំលេខទូរស័ព្ទរបស់ មុន្នី ទេ មកដល់មុខមន្ទីពេទ្យជីភូ មុន្នីបានឡើងជិះឡានខ្លួនបាំងខាងក្រោយជិតស្រីរងគ្រោះហើយ មុន្នី ធ្វើជានិយាយថា ឲ្យខ្លួនបើកឡានទៅយកពួកម៉ាកនៅម្តុំមេសថ្នូកម្នាក់ទៀត ពេលទៅដល់មុន្នីថាពួកម៉ាកវាទៅបាត់ហើយចាំយូរពេក ហើយក៏បានបើកមកបាវិតតាមផ្លូវលំហួសថ្នល់កែងប្រហែល១០០ពាមុន្នី ចាប់ផ្តើមធ្វើសកម្មភាពចងដៃជនរងគ្រោះទៅក្រោយចាប់រំលោភជនរងគ្រោះលើឡានរបស់ខ្លួនរហូតជនរងគ្រោះសន្លប់ ពេលមកដល់ផ្លូវចូលរោងចក្រឃីងមេខ័រក៏ឈប់ឡាន មុន្នី ចុះពីឡានខ្លួនក៏បានទៅរំលោភជនរងគ្រោះម្តងរួចហើយប្រាប់ មុន្នី ថាកុំឲ្យសម្លាប់គេតែវាថាកុំទុកខ្លាចមានរឿង មុន្នី យកកន្សែងទាក់កកន្ទ្រាក់ជនរងគ្រោះទម្លាក់ពីលើឡានរួចហើយអូសជនរងគ្រោះទៅទម្លាក់ក្នុងទឹកស្រែយកដុំថ្មសង្កត់ពីលើ ពីមុនមកពុំដែលមានទំនាស់ជាមួយមុន្នី ពីមុនមកខ្លួនជាមួយមុន្នី ធ្លាប់បានចាប់រំលោភលើស្រីវៀតណាមម្តងដែរ ខ្លួនពុំបានឆ្លើយទម្លាក់កំហុសលើ មុន្នី ហើយចម្លើយនេះជាការពិត ។ ពេលសមត្ថកិច្ចឃាត់ខ្លួនពិតជាមានខ្សែក និង ខ្សែដៃរបស់ជនរងគ្រោះនៅក្នុងឡានរបស់ខ្លួនមែន ខ្លួនសុំឲ្យតុលាការបន្ធូរបន្ថយទោស ។ ជនជាប់ចោទសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសគឺជនជាប់ចោទបានទទួលស្គាល់អង្គហេតុ និង សេចក្តីសម្រេចអំពីទោសដែលតុលាការបានប្រកាសលើជនជាប់ចោទ[redacted] សុជាតិ រួចហើយ ក៏មានភស្តុតាងដាក់បន្ទុកលើ [redacted] សុជាតិ នេះដូចជាចម្លើយសារភាពរបស់ជនជាប់ចោទ សាក្សីបានឃើញឡានរបស់ [redacted] សុជាតិ នៅកន្លែងកើតហេតុ សមត្ថកិច្ចផ្ទៀងផ្ទាត់កាំម៉ារ៉ាគឺជាឡានរបស់ជនជាប់ចោទ ខ្សែករបស់ជនរងគ្រោះនៅឡានរបស់ជនជាប់ចោទនោះជាភស្តុតាងបញ្ជាក់ពីពិរុទ្ធភាព លើជនជាប់ចោទ[redacted]ជាតិ ។ នាសវនាការនេះជនជាប់ចោទបានជំទាស់ និង ការសម្រេចអំពីសំណងរដ្ឋប្បវេណីនិង ការសម្រេចរឹបអូសរថយន្តម៉ាកហាយឡិនឌ័រពណ៌ស ផ្លាកលេខ ២A00៥២៥ ការសម្រេចឲ្យជនជាប់ចោទ ឆឹយ សុជាតិ រួមគ្នាសងសំណងចំនួន ៦០០០០$ ទៅឲ្យដើមបណ្តឹងសមរម្យហើយព្រោះដើមបណ្តឹងបាត់បង់កូនហើយបានចំណាយប្រាក់ផ្សេងៗ និង ធ្វើបុណ្យឲ្យកូនប៉ះពាល់ទាំងផ្លូវចិត្តរហូត ។ ចំពោះរថយន្តហាយឡេនឌ័រជាវត្ថុតាងប្រព្រឹត្តបទល្មើសគប្បីរឹបអូសដាក់ជាសម្បត្តិរដ្ឋ ។

៤-ជនជាប់ចោទ[redacted] សូនី ហៅ មុន្នី ឆ្លើយបដិសេធថា ពុំបានចូលរួមប្រព្រឹត្តបទល្មើសនេះឡើយ ថ្ងៃកើតហេតុទី០២ ខែសីហា ឆ្នាំ២០១៧ ពេលព្រឹកខ្លួនទៅដឹកចិនចេញពីការស៊ីណូម៉ាកការនៅឯបាវិតឆ្ពោះទៅប្រលានយន្តហោះភ្នំពេញដល់ព្រលានយន្តហោះភ្នំពេញម៉ោងប្រហែល ១១ ថ្ងៃត្រង់បានដាក់ ភ្ញៀវចុះហើយក៏ចូលបាយនៅព្រលានបាយរួចក៏បានមករកម៉ូយជិះឡានផ្សារអូឡាំពិករកបានមួយខ្លះ ដល់ម៉ោងជិត១រសៀលបានបើកឡានចេញមកខេត្តស្វាយរៀងវិញមានមួយជិះឡានខ្លួនចុះតាមផ្លូវខ្លះហើយនៅសល់បីនាក់ខ្លួនជូនដាក់ចុះនៅផ្សារប្រសូតបន្ទាប់មកខ្លួនចូលដឹកតុ និង កៅអី១០ដែកអីណុកយកពីផ្ទះតុលា ទៅឲ្យឈ្មោះ វ៉ាន នៅឯភូមិព្រៃតាញ៉យជិតផ្ទះខ្លួន ពេលទៅដល់ខ្លួនចាំថាប្រហែលម៉ោង ០៥:៣០នាទី ព្រោះពេលនោះកម្មករចេញពីរោងចក្រ ដាក់តុកៅអីហើយខ្លួនលាងឡាននៅផ្ទះរហូតដល់ម៉ោង៦ល្ងាចជាងពុំ



Scanned with CamScanner

បានទៅណាទេ ខ្លួនពុំបានទូរស័ព្ទទៅ[redacted]សុជាតិ ពុំបានជួប[redacted]សុជាតិ នៅអ្នកលឿងពុំបានចាំនៅមន្ទីរពេទ្យជីភូ ពុំបានជិះឡានវា ហើយពុំបានចាប់រំលោភសម្លាប់ជនរងគ្រោះដូចវាបានចោទប្រកាន់ឡើយ ។ ខ្លួនពុំបានរំលោភស្ត្រីជនជាតិវៀតណាម ឈ្មោះ [redacted]សុជាតិ ចង់ធ្វើបាបខ្លួន ព្រោះពីមុនធ្លាប់មានទំនាស់ព្រំដីហើយធ្លាប់វាយតប់គ្នាដណ្តើមមួយនៅបេនឡាន ។ នៅថ្ងៃពុំចាំខ្លួនបានផឹកកង់ឲ្យគេដាក់នៅជិតផ្ទះរបស់ [redacted]សុជាតិ ពេលនោះវាឃើញខ្លួនបានកៀកកខ្លួនឲ្យចូលផឹកស៊ីផ្ទះរបស់វា ផឹកបានបន្តិចខ្លួនចេញមកវិញពួកវាសុំលុយ ១៥០០០៛០ ទិញស្រាបៀរថែម ។ ខ្លួនពុំស្គាល់លេខទូរស័ព្ទរបស់[redacted] សុជាតិ ទេ ខ្លួនមានសាក្សីដឹងឮថ្ងៃកើតហេតុ ផឹកតុ កៅអី និងនៅផ្ទះចាប់ពី ម៉ោង៥ជាង សំបុត្រឡានចូលប្រលានយន្តហោះបោះចោលហើយខ្លួនសុំឲ្យតុលាការ លើកលែងចោទប្រកាន់ឃើញថាជនជាប់ចោទ [redacted]សូនី បានឆ្លើយបដិសេធតាំងពីពេលសមត្ថកិច្ចឃាត់ខ្លួនរហូតមកដល់ពេលសវនាការនេះ តែចម្លើយដាក់បន្ទុករបស់ [redacted]សុជាតិ ក៏ពុំមានការប្រែប្រួលដែរ គឺ[redacted]សុជាតិ បានបញ្ជាក់ដូចខាងលើថា [redacted]សូនី ជាអ្នកចងដៃរំលោភសេពសន្ថវៈលើជនរងគ្រោះមុន រួចហើយសុជាតិរំលោភជនរងគ្រោះតាមក្រោយរួចយកកន្សែងទាក់កជនរងគ្រោះពន្រ្ទាក់ចុះពីឡានហើយអូសជនរងគ្រោះទៅទំលាក់ក្នុងទឹកយកថ្មសង្កត់ពីលើ ។

៥-តាមចម្លើយឲ្យការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីឡូត ថាថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ កូនស្រីរបស់ខ្លួនឈ្មោះ [redacted]សុម៉ាលីន ធ្វើដំណើរត្រលប់ទៅបាវិតវិញខ្លួនបានទូរស័ព្ទសួរកូនតាមផ្លូវហូរហែម៉ោង១២ថ្ងៃកូនខ្លួនដល់ភ្នំពេញ ម៉ោង៥ល្ងាចកូនក្តីខ្លួនថា ដល់ខេត្តស្វាយរៀងត្រង់ចំណុចផ្សារជីភូ កូនប្រាប់ថា ឡានតាក់ស៊ីនោះឈប់ចាំដាក់មនុស្សម្នាក់ទៀតហើយឡាននោះបើកតាមផ្លូវលំកូនប្រាប់ថា វាពុំស្គាល់ផ្លូវនេះទេ ។ ម៉ោងប្រហែល៦ល្ងាចខ្លួនតេទៅកូនលែងចូលរហូតដល់ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៧ ខ្លួនបានបារម្ភពីកូនខ្លាំងក៏មកស្វាយរៀងដាក់ពាក្យប្តឹង សមត្ថកិច្ចស្រាវជ្រាវរកឃើញសពកូនហើយដឹកសពយកមកធ្វើបុណ្យ ។ ចម្លើយឲ្យការណ៍របស់ដើមបណ្តឹងស៊ីចង្វាក់និងចម្លើយសារភាពរបស់ [redacted]សុជាតិ ទាំងពេលវេលា និង កន្លែងដែល[redacted]សុជាតិ ឈប់នៅមន្ទីរពេទ្យជីភូដើម្បីយកបក្ខពួកខ្លួនដើម្បីសហការគ្នាប្រព្រឹត្តបទល្មើស ។ តាមស្តាប់ចម្លើយសាក្សីឈ្មោះ [redacted]សារី និងប្តីឈ្មោះ [redacted] សាមុត បានបញ្ជាក់កាលនៅសាលាដំបូងថា ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ៦:៣០នាទីពេលខ្លួនជិះម៉ូតូចេញពីធ្វើការរោងចក្រឃើញឡានពណ៌ស១គ្រឿងពុំស្គាល់ម៉ាកឈប់លើចិញ្ចើមផ្លូវម្តុំសាកសពក្មេងស្រីនោះពុំឃើញមានមនុស្សនៅក្បែររថយន្តទេ លុះដល់ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ ឮគេនិយាយថាមានសាកសពក្មេងស្រីស្លាប់នៅម្តុំកន្លែងរថយន្តដែលខ្លួនឃើញឈប់បីថ្ងៃមុន ។ សមត្ថកិច្ចបានស្រាវជ្រាវឲ្យសាក្សីពីរនាក់នេះចង្អុលបង្ហាញរថយន្តពណ៌ស សាក្សីបានបង្ហាញថារថយន្តដែលឈប់ក្បែរសាកសពជាប្រភេទរថយន្តហាយលេនឌ័រសមត្ថកិច្ចបានពិនិត្យកាំម៉ារ៉ារោងចក្រឃីងមេខ័រឃើញឡានបើកកាត់នោះម៉ោង៦និង៤៥នាទី ថ្ងៃទី០២ ខែសីហា ឆ្នាំ ២០១៧ ប្រភេទឡានហាយលេនឌ័រពណ៌ស ។ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ សមត្ថកិច្ចបានឃាត់ខ្លួន[redacted] សុជាតិ ដំបូង [redacted] សុជាតិ បដិសេធលុះដល់មត្តកិច្ចហៅម្តាយមីងរបស់សពឈ្មោះ [redacted] ចន្ទ ចង្អុលបង្ហាញខ្សែក ចិញ្ចៀន ដែលសមត្ថកិច្ចបានដកហូតពីឡានរប[redacted]សុជាតិ ថា ពិតជារបស់ស[redacted] សុម៉ាលីន ទើបជនជាប់ចោទ [redacted]សុជាតិ ឆ្លើយសារភាពហើយ [redacted]សុជាតិ បញ្ជាក់ថាខ្លួន និង ឈ្មោះ [redacted]សូនី ជាអ្នកប្រព្រឹត្តបទល្មើសក្នុងរឿងនេះហើយសមត្ថកិច្ចក៏បន្តឃាត់ខ្លួនជនជាប់ចោទឈ្មោះ[redacted]សូនី ។ ចម្លើយដាក់បន្ទុកអាចឲ្យតុលាការពិចារណាបានព្រោះថា អង្គហេតុរំលោភសម្លាប់អូសសពជនរងគ្រោះយកទៅទំលាក់ក្នុងទឹក

ស្រែ យកជុំថ្មសង្កត់ពុំអាច[redacted]សុជាតិ ធ្វើម្នាក់ឯងបានទេ ព្រោះថាអំពើនេះអាចជនជាប់ចោទ រំលោភ តាមឡានរួចទើបដឹកជនរងគ្រោះទៅកន្លែងទម្លាក់សពហើយ[redacted]សុជាតិ ជាអ្នកបើកឡានត្រូវតែមានគ្នី គ្នាចាប់ជនរងគ្រោះនៅពេលឡាននោះបើកបរកាត់ផ្លូវលំ ។ ចម្លើយដោះសាររបស់ [redacted] សូនី ថា៖ [redacted] សុជាតិ ឆ្លើយទំលាក់កំហុសដាក់ខ្លួនដោយសារធ្លាប់ឈ្លោះគ្នារឿងព្រំដី និង ធ្លាប់វាយគ្នាដណ្តើមមុយគ្មាន ភស្តុតាងបញ្ជាក់ទេ ផ្ទុយទៅវិញមុនពេលសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted] សូនី បានទៅចូលរួមបុណ្យ និង បានផឹកស៊ីនៅផ្ទះរបស់ [redacted] សុជាតិ ថែមទៀតសបញ្ជាក់កាន់តែច្បាស់ថាពុំមានការឈ្លោះគ្នារវាង [redacted] សុជាតិ និង [redacted] សូនី ឡើយ ។ ក្រុមប្រឹក្សាយល់ឃើញថា ឈ្មោះ [redacted] សូនី ពិតជាសហការីបានប្រព្រឹត្ត បទល្មើសឃាតកម្មដោយមានទារុណកម្ម និង រំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសតាមមាត្រា ២០៥ នៃក្រម ព្រហ្មទណ្ឌត្រូវមានទោសដាក់ពន្ធនាគារអស់មួយជីវិត ។

៦-តាមស្តាប់ចម្លើយរបស់សាក្សី [redacted] សុខខេង, [redacted] យ៉ូន, [redacted] ធឿង, [redacted]ដេត[redacted]សុវណ្ណរី, បាន បញ្ជាក់ប្រហាក់ប្រហែលគ្នាថា ពួកខ្លួនបានដឹងថាឈ្មោះ [redacted]សុជាតិ និងឈ្មោះ [redacted] សូនី មានទំនាស់ពុំ ត្រូវគ្នាប្រហែល៣ខែមុនពេលឃាត់ខ្លួន ចម្លើយសាក្សីពុំមានភស្តុតាងបញ្ជាក់ឲ្យធ្វើបានឡើយ ម្យ៉ាងសាក្សី ថាបានដឹងរឿងនេះឈ្មោះ [redacted]សូនី និយាយប្រាប់ ប៉ុន្តែបើពិនិត្យចម្លើយសាក្សី [redacted]ង៉ុន, [redacted] សាវ៉ាន់ ចម្លើយរបស់ជនជាប់ចោទ [redacted] សុជាតិ មុនសមត្ថកិច្ចឃាត់ខ្លួន ផ្ទះរបស់ [redacted] សុជាតិ មានកម្មវិធីសូត្រ មន្តហើយ[redacted]សូនី បានទៅចូលរួម និង ផឹកស៊ីនៅទីនោះ ក្រុមប្រឹក្សាយល់ឃើញថាមនុស្សឈ្លោះគ្នាវាយ តប់គ្នាហើយពុំអាចទៅចូលរួមកម្មវិធីនោះឡើយ ។

៧-សាក្សីដោះបន្ទុកឈ្មោះ [redacted] សូន្យ ប្រពន្ធជនជាប់ចោទសាក្សីឈ្មោះ[redacted] ស៊ីភួន, [redacted] សារុំ, [redacted]វុធ, [redacted] វ៉ាន, [redacted] សាវ៉ាន, [redacted] សារិន[redacted]តុលា បានឃើញ [redacted] សូនី ដឹកតុ និងកៅអី នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង៤:៤០នាទី រួចហើយឈ្មោះ [redacted]សូនី នៅផ្ទះពុំបានទៅណាទេ ចម្លើយ របស់សាក្សីដោះបន្ទុកនេះតុលាការពុំអាចជឿបានឡើយ ព្រោះពុំមានភស្តុតាងបញ្ជាក់បន្ថែម ម្យ៉ាងសាក្សី ដោះបន្ទុកនេះផ្ទុយពីអង្គហេតុពិតដែលតុលាការនៅជឿជាក់ថា ពេលប្រព្រឹត្តបទល្មើសនោះគឺឈ្មោះ [redacted] សូនី ពិតជាបានចូលធ្វើជាមួយ[redacted] សុជាតិ ព្រោះ[redacted]សុជាតិ បានអះអាងច្បាស់ហើយខ្លួនឆ្លើយការពិត ហើយពុំមានផលប្រយោជន៍អ្វីទេក្នុងការធ្វើដាក់ឈ្មោះ [redacted]សូនី នេះ ។ ក្រុមប្រឹក្សាយល់ឃើញថា៖ បើសិ[redacted]សូនី ពុំបានចូលរួមប្រព្រឹត្តបទល្មើសនេះទេ ឈ្មោះ [redacted]សុជាតិ ក៏ពុំឆ្លើយដាក់ដែរ ។

៨-មេធាវីការពារសិទ្ធឲ្យដើមបណ្តឹងសន្និដ្ឋាន ពុំតំកល់សាលក្រម របស់សាលាដំបូង ឃើញថា

មានលក្ខណៈត្រឹមត្រូវហើយគប្បីតុលាការពិចារណា ។

៩-តំណាងមហាអយ្យការសន្និដ្ឋានមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ [redacted] សុជាតិ អំពើ ប្រព្រឹត្តមានលក្ខណៈឃោរឃៅរំលោភសម្លាប់មានផែនការច្បាស់លាស់ដូចមានបញ្ញតិមាត្រា២០៥នៃក្រម ព្រហ្មទណ្ឌ សុំតំកល់សាលក្រមលើឈ្មោះ [redacted]សុជាតិ ។ ជនជាប់ចោទ[redacted] សូនី បានឆ្លើយបដិសេធ គ្រប់ដំណាក់កាលហើយក៏មានសាក្សីដោះបន្ទុកផងដែរ ការសម្រេចផ្តន្ទាទោសលើ [redacted] សូនី ពុំមាន ភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទេ គប្បីចាត់របៀបដើម្បីស៊ើបអង្កេតបន្ថែមដូចជាការទាក់ទងគ្នាតាមទូរស័ព្ទ មុននិងប្រព្រឹត្តបទល្មើស ។ អាចមានអ្នកផ្សេងប្រព្រឹត្តជាមួយឈ្មោះ [redacted] សុជាតិ តែជនជាប់ចោទពុំប្រាប់ តុលាការ ។ សេចក្តីសន្និដ្ឋានលើឈ្មោះ [redacted]សុជាតិ មានលក្ខណៈត្រឹមត្រូវព្រោះសេចក្តីសន្និដ្ឋានលើ

ជនជាប់ចោទ [redacted] សូនី របស់តំណាងអយ្យការសុំឲ្យចាត់របៀបរកទូរស័ព្ទទាក់ទងរបស់ជនជាប់ចោទទាំងពីរនាក់មុនកើតហេតុសាលាដំបូងបានចាត់របៀបបំពេញកិច្ចស៊ើបសួររួចហើយគឺលទ្ធផលរបស់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាលេខ ៤៥៦ រ.ប.ប.ប/៦.៦.២០១៨ ប្រព័ន្ធទូរស័ព្ទទាំង៣ ក្រុមហ៊ុនពុំអាចផ្តល់មកការិយាល័យជំនាញបានទេ ព្រោះក្រុមហ៊ុនទូរស័ព្ទរក្សាទិន្ន័យទូរស័ព្ទបានតែ ៩០ ថ្ងៃប៉ុណ្ណោះ ។ ចំពោះការលើកឡើងរបស់តំណាងមហាអយ្យការថា អាចមានអ្នកផ្សេងទៀតធ្វើជាមួយ [redacted] សុជាតិ គឺលើកឡើងនេះពុំមានមូលដ្ឋានច្បាស់លាស់ ។

១០-មេធាវីលោក [redacted] សំអាត ការពារសិទ្ធិឲ្យជនជាប់ចោទ [redacted] សុជាតិ សន្និដ្ឋានកូនក្តីខ្លួនបានឆ្លើយសារភាពទទួលស្គាល់កំហុសកូនក្តីខ្លួនបានឃាត់ [redacted] សូនី កុំឲ្យសម្លាប់ជនរងគ្រោះតែ សូនី ពុំស្តាប់ ។ កូនក្តីខ្លួនពុំដែលមានទំនាស់ជាមួយ [redacted] សូនី ទេ ហើយការដែលកូនក្តីខ្លួនឆ្លើយថាប្រព្រឹត្តបទល្មើសជាមួយ [redacted]នី នេះជាការពិត ព្រោះ [redacted] សូនី ជាអ្នកចូលរួមធ្វើសកម្មភាពរំលោភនិង សម្លាប់ជនរងគ្រោះ ។ សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ [redacted] សុជាតិ និងសុំទាមទាររថយន្តដើម្បីទុកចិញ្ចឹមប្រពន្ធកូនឲ្យ [redacted] សុជាតិវិញ។ការសុំបន្ធូរបន្ថយទោសរបស់ជនជាប់ចោទ [redacted] សុជាតិ ពុំអាចពិចារណាបានទេ ព្រោះអំពើដែលជនជាប់ចោទនេះបានប្រព្រឹត្តមានលក្ខណៈឃោរឃៅព្រៃផ្សៃ រំលោភហើយធ្វើទារុណកម្មលើជនរងគ្រោះរហូតដល់ស្លាប់ នេះបើតាមកំណត់ហេតុពិនិត្យសាកសពជនរងគ្រោះ ។ ហើយការប្រព្រឹត្តនេះពុំចូលទៅក្នុងលក្ខខណ្ឌស្ថានសំរាលទោសតាមមាត្រា ៩៣, ៩៤ នៃក្រមព្រហ្មទណ្ឌនោះឡើយ ។ ចំពោះការសុំទាមទាររថយន្តជាវត្ថុតាងប្រព្រឹត្តបទល្មើសនោះមានសំអាងហេតុខាងលើរួចហើយ វត្ថុតាងប្រព្រឹត្តគប្បីរឹបអូសទុកជាសម្បត្តិរដ្ឋ ។

១១-មេធាវី [redacted] សម្បត្តិ ការពារសិទ្ធឲ្យជនជាប់ចោ[redacted]សូនី សុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទកូនក្តីខ្លួនពុំបានប្រព្រឹត្តបទល្មើសនេះជាមួយ [redacted] សុជាតិ ទេ តុលាការជឿតែលើចម្លើយដាក់បន្ទុករបស់ [redacted] សុជាតិ ម្នាក់គត់ តុលាការពុំបានពិចារណាលើចម្លើយរបស់កូនក្តីខ្លួន និង សាក្សីដោះបន្ទុកជាច្រើននាក់ដែលបានឃើញ ពេលកើតហេតុរំលោភសម្លាប់ជនរងគ្រោះនោះកូនក្តីខ្លួននៅដឹកតុ កៅអីឯផ្សារប្រសូតយកទៅឲ្យអ្នកទិញឈ្មោះ វ៉ាន នៅភូមិព្រៃញ៉យហើយកូនក្តីខ្លួនលាងឡាននិងនៅផ្ទះរហូតមក ។ ចម្លើយដាក់បន្ទុករបស់[redacted]សុជាតិ ក៏មានការប្រែប្រួលតុលាការពុំបានស្រាវជ្រាវរកភស្តុតាងទូរស័ព្ទទាក់ទងរបស់ និង កូនក្តីខ្លួនហើយសម្រេចផ្តន្ទាទោសលើកូនក្តីខ្លួនដោយអយុត្តិធម៌ ។ ការប្តឹងសុំឲ្យជនជាប់ចោទរួចខ្លួនពុំអាចពិចារណាបាន ព្រោះគ្មានភស្តុតាងដោះបន្ទុកទេ ។

១២-សាលក្រមព្រហ្មទណ្ឌលេខ ២០០"ឃ" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង បានលើកយកសំអាងហេតុ និង បានសម្រេចសេចក្តីត្រឹមត្រូវតាមច្បាប់ហើយគួរតំកល់ទុកជាបានការ ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទ [redacted] សុជាតិ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងអង្គច្បាប់ ។



Scanned with CamScanner

២-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៤៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទ [redacted] សូនី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២០០(ឃ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀងទុកជាបានការទាំងមូលដដែល ។

៤-បន្តការឃុំខ្លួនជនជាប់ចោទតាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២០ ចំពោះមុខជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២០ កំបាំងមុខជនជាប់ចោទតែចាត់ជាចំពោះមុខ និង ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] [redacted] | ហត្ថលេខា: [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំជូតទោស័ក ព.ស.២៥៦៣

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២០

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner